Sacombank

# គោលការណ៍ និងលក្ខខណ្ឌ
# របស់កម្មវិធីប្រូម៉ូសិនជាមួយប័ណ្ណឥណទានវីសា

I. **ផលិតផល៖** ប័ណ្ណឥណទានវីសា របស់ធនាគារ សាខមប៉ែង ខេមបូឌា

II. **ព័ត៌មានលម្អិតអំពីកម្មវិធីប្រូម៉ូសិន៖**

| **សម្រាប់អតិថិជនថ្មី** | |
|---|---|
| **រយៈពេលនៃការអនុវត្ត៖** | **ការផ្តល់ជូន** |
| ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ | ឥតគិតកម្រៃសេវាប្រចាំឆ្នាំសម្រាប់ឆ្នាំដំបូង |
| | ទទួលបានប្រាក់សងត្រឡប់២០% (អតិបរិមា ១០ដុល្លា) សម្រាប់ការបញ្ជាទិញដំបូង តាមរយៈប័ណ្ណឥណទានវីសា |

III. **អតិថិជន សម្រាប់អតិថិជនថ្មី**

**ការផ្តល់ជូននេះ**គឺសម្រាប់ម្ចាស់ប័ណ្ណដែលជា**អតិថិជនថ្មី**មានគ្រប់លក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- អតិថិជនមិនធ្លាប់មានប័ណ្ណឥណទានវីសាធនាគារសាខមប៉ែងពីមុនមកហើយធ្វើការស្នើសុំប័ណ្ណឥណទានវីសាទទួលបានការអនុម័តនិងចេញប័ណ្ណឱ្យប្រើប្រាស់ក្នុងអំឡុងពេលនៃកម្មវិធី **ប្រូម៉ូសិន។**
- ចំពោះប័ណ្ណឥណទានវីសាដែលមានទ្រព្យធានា(Secure Credit Card)នឹងទទួលបានការមិនគិតកម្រៃសេវាផ្ញើឯកសារ។
- ប្រតិបត្តិការគ្រប់លក្ខខណ្ឌគឺជាប្រត្តិបត្តិការដែលធ្វើឡើងដោយការបញ្ជាទិញទំនិញ និងសេវាកម្មតាមរយៈប័ណ្ណឥណទានវីសា(មិនរួមបញ្ចូលប្រត្តិបត្តិការដកសាច់ប្រាក់)។
- ប្រត្តិបត្តិការប័ណ្ណរងឥណទាននឹងត្រូវកត់ត្រាទុកសម្រាប់ប័ណ្ណចំបង។
- ម្ចាស់ប័ណ្ណម្នាក់ៗអាចទទួលបានទឹកប្រាក់ត្រឡប់មកវិញសម្រាប់ ប្រត្តិបត្តិការដែលគ្រប់លក្ខខណ្ឌដំបូង។
- ប្រត្តិបត្តិការដែលមិនបានប្រកាស ឬលុបចោល ឬសងមកវិញ នឹងត្រូវកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌ។
- ការផ្តល់ជូននេះមានចំនួនកំណត់អតិថិជនធ្វើប្រតិបត្តិការមុននិងទទួលមុនរហូតដល់គ្រប់ចំនួនកំណត់។

IV. **លក្ខខណ្ឌផ្សេងទៀត**

- ប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌអាចធ្វើឡើងដោយម្ចាស់ប័ណ្ណចម្បង និងម្ចាស់ប័ណ្ណរង។
- ប្រតិបត្តិការដែលជោគជ័យ ( ម្ចាស់ប័ណ្ណនឹងទទួលបានសារជូនដំណឹងពីធនាគារ ) ប៉ុន្តែបើក្នុងរយៈពេល៣០ថ្ងៃ ប្រតិបត្តិការទាំងនោះមិនបានកត់ត្រាចូលទៅក្នុងរបាយការណ៍នឹងត្រូវចាត់ទុកជាប្រតិបត្តិការមិនគ្រប់លក្ខខណ្ឌ។
- វិវាទ ការលុបចោល និង/ឬ ប្រតិបត្តិការបរាជ័យក្នុងអំឡុងពេលប្រូម៉ូសិន នឹងត្រូវកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌ។
- រាល់ប្រតិបត្តិការដែលមានការសង្ស័យ ឬមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដោយផ្អែកលើពេលវេលាទីតាំងរបស់ ប្រតិបត្តិការ ឬកត្តាផ្សេងទៀត នឹងត្រូវកាត់ចេញពីប្រតិបត្តិការដែលមានសិទ្ធិមុន។ ធនាគារមានសិទ្ធិក្នុងការស្នើសុំអតិថិជន ក្នុងការផ្តល់វិក័យបត្រហិរញ្ញវត្ថុដើម្បីបញ្ជាក់ពីភាពត្រូវត្រឹមត្រូវរបស់ប្រតិបត្តិការ។ ក្នុងករណីដែលអតិថិជនខកខានមិនបានបង្ហាញពីភាពត្រឹមត្រូវរបស់ប្រតិបត្តិការនោះទេ ធនាគារនឹងធ្វើការកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌនោះ។

- ធនាគារសាខមប៉ែង មានសិទ្ធិបដិសេធនូវរាល់ពាក្យស្នើសុំដែលមិនគ្រប់លក្ខខណ្ឌមិនច្បាស់លាស់ មិនគ្រប់គ្រាន់ និង/ឬ ឯកសារយោងមិនសមស្រប។

## V. ព័ត៌មានបន្ថែម

- សម្រាប់ព័ត៌មានបន្ថែមអតិថិជនអាចអញ្ជើញមកកាន់សាខាណាមួយរបស់ធនាគារសាខមប៉ែងខេមបូឌា ឬទំនាក់ទំនងមកកាន់ភ្នាក់ងារបម្រើអតិថិជន៖ ០២៣ ២២៣ ៤២៣ និង ០៩៧៨ ២២៣ ៤២៣។
- ធនាគារសាខមប៉ែងខេមបូឌាទទួលខុសត្រូវ ក្នុងការជូនដំណឹងទៅលើគោលការណ៍ និងលក្ខខណ្ឌនៃកម្មវិធីនេះ និងព័ត៌មានរបស់អតិថិជនដែលគ្រប់លក្ខខណ្ឌ( រួមមាន ឈ្មោះ លេខអត្តអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែននិងលេខបួនខ្ទង់ចុងក្រោយរបស់ប័ណ្ណឥណទានវីសា)តាមរយៈគេហទំព័ររបស់ធនាគារសាខមប៉ែងខេមបូឌា៖ sacombank.com.kh ដោយមិនជូនដំណឹងជាមុន។

## VI. លក្ខខណ្ឌទូទៅ

- ធនាគារសាខមប៉ែងខេមបូឌា មិទទួលខុសត្រូវ ចំពោះការមិនបានជូនដំណឹង ដោយសារបញ្ហាប្រព័ន្ធ Email អាសយដ្ឋាន ឬលេខទូស័ព្ទដែលផ្តល់ដោយម្ចាស់ប័ណ្ណ ឬលិខិតជូនដំណឹងត្រូវបាត់ លួច ឬខូច។
- ដោយមានការយល់ព្រមពីអតិថិជន ធនាគារសាខមប៉ែងសូមរក្សារសិទ្ធិជាសាធារណៈក្នុងការបង្ហាញឈ្មោះ និងរូបភាពរបស់អតិថិជន ទៅក្នុងការប្រកាសនិងផ្សាយពាណិជ្ជកម្មតាមការសែតប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដោយមិនពុំចាំបាច់ផ្តល់កម្រៃសេវា ណាមួយទៅកាន់អតិថិជនឡើយ។
- ធនាគារសាខមប៉ែង សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌទាំងនេះនៅពេលណាមួយដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុន។
- ក្នុងករណីមានវិវាទណាមួយកើតឡើងទាក់ទងនឹងកម្មវិធីប្រូម៉ូសិននេះធនាគារសាខមប៉ែង និងដោះស្រាយវិវាទនេះយ៉ាងសមស្របបំផុតទៅកាន់អតិថិជន ប្រសិនបើបរាជ័យក្នុងការដោះស្រាយវិវាទ នោះវិវាទនឹងត្រូវបានដោះស្រាយទៅតាមផ្លូវច្បាប់ដែលបានកំណត់។
- តាមរយៈការចូលរួមក្នុងកម្មវិធីនេះ គ្រប់ម្ចាស់ប័ណ្ណទាំងអស់ ត្រូវចាត់ទុកថាទទួលនិងយល់ព្រមនូវគោលការណ៍ និងលក្ខខណ្ឌរបស់កម្មវិធី។